នស/រកត/០៦០២/១៦៣

# ព្រះរាជក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ទិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាព ពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងសុខាភិបាល ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ "ក" ដូចមានចែងក្នុងមាត្រា៣ នៃ ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ របស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រសុខាភិបាលកំរិតឧត្តម បំរើការងារក្នុងវិស័យសុខាភិបាល នៅតាមអង្គភាពជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈ របស់ក្រសួងស្ថាប័នរដ្ឋ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មានមុខងារក្នុងដំណែងគ្រប់គ្រង ដឹកនាំ សិក្សាស្រាវជ្រាវ និងផ្តល់យោបល់ផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តវេទនសាស្ត្រ ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលជាន់ខ្ពស់ មាន ១៤ ថ្នាក់ ។

**មាត្រា ៥.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ អាចកាន់មុខដំណែងគ្រប់គ្រង នៅតាមអង្គភាពបច្ចេកទេសជំនាញនានា របស់ក្រសួងសុខាភិបាលដូចខាងក្រោម :៚

- ឋានន្តរស័ក្តិទី ១ : អគ្គនាយកបច្ចេកទេសជំនាញ អគ្គាធិការបច្ចេកទេសជំនាញ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

- ឋានន្តរស័ក្តិទី ២ : អគ្គនាយករងបច្ចេកទេសជំនាញ អគ្គាធិការរងបច្ចេកទេសជំនាញ សាកលវិទ្យាធិការរង អធិការបច្ចេកទេសជំនាញ ព្រឹទ្ធបុរសមហាវិទ្យាល័យ ប្រធាននាយកដ្ឋានបច្ចេកទេសជំនាញ

- ឋានន្តរស័ក្តិទី ៣ : ព្រឹទ្ធបុរសរងមហាវិទ្យាល័យ អនុប្រធាននាយកដ្ឋានបច្ចេកទេសជំនាញ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង និង មុខដំណែងបច្ចេកទេស វិទ្យាសាស្ត្រសុខាភិបាលឯទៀត ដែលមានថ្នាក់ស្មើនឹងមុខដំណែងខាងលើ នៃឋានន្តរស័ក្តិនីមួយៗ នៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៦.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជានិស្សិត និង ឬជាមន្ត្រីរាជការ ។ ចំនួនតំណែង ក្នុងការជ្រើសរើសសំរាប់បេក្ខជន ជានិស្សិត និងសំរាប់បេក្ខជនជាមន្ត្រីរាជការ តាមផ្នែកនីមួយៗ ត្រូវកំណត់ឡើង ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៧.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ ក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រតាមផ្នែកណាមួយ យ៉ាងទាបត្រឹមសញ្ញាប័ត្រសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ផ្នែកវេជ្ជសាស្ត្រ ផ្នែកឱសថសាស្ត្រ ឬផ្នែកទន្តវេទសាស្ត្រ ឬ សញ្ញាប័ត្រ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តវេទសាស្ត្រ ផ្សេងទៀតដែលមានតំលៃស្មើ ។

ចំពោះមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌ នៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.-**

បេក្ខជន ដែលបានជ្រើសរើស តាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូង រៀបចំដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលជាន់ខ្ពស់ ។ ល។

មាត្រា ៩.-

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវចាត់អោយទៅបំរើការងារ នៅតាមអង្គភាពសុខាភិបាល ខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវតែងតាំង ជាមន្ត្រីសុខាភិបាលជាន់ខ្ពស់កម្មសិក្សា ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

— មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីសុខាភិបាលជាន់ខ្ពស់ផ្នែកវេជ្ជសាស្ត្រ ត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៣ ហើយ មន្ត្រីសុខាភិបាលជាន់ខ្ពស់ផ្នែកផ្សេងទៀត ត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

— មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលជ្រើសរើសចេញពីមន្ត្រីរាជការរបស់ក្រសួងសុខាភិបាល ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ មន្ត្រីរាជការផ្សេងៗទៀត ត្រូវធ្វើកម្មសិក្សា សាកល្បងរយៈពេល ០៦ ខែ ។

— មន្ត្រីសុខាភិបាលជាន់ខ្ពស់ដែលជ្រើសរើសតាមការប្រលងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

— មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលធ្វើកម្មសិក្សា មិនបានសំរេចជោគជ័យ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ទៀត ។ ក្នុងករណីមិនទទួលបានជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការ ត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូងនិងកម្មសិក្សា សំរាប់អតីតភាពការងារ ។

— ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

មាត្រា ១០.-

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់អាចត្រូវតែងតាំង ក្នុងមុខតំណែងទំនេរណាមួយដូចមានកំណត់ក្នុងមាត្រា៣ និងមាត្រា៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចមានកំណត់ ក្នុងមាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការដាក់ឱ្យស្ថិតក្រៅក្របខ័ណ្ឌដើម

មាត្រា ១១.-

មន្ត្រីសុខាភិបាលជាន់ខ្ពស់ អាចត្រូវដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើមឬ ក្រៅដំណែងដើម ដើម្បីទៅបំរើការងារទៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពផ្សេងទៀត តាមតម្រូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។ល។

# ជំពូកទី ៧

## ការដំឡើងឋានន្តរស័ក្តិ និង ការដំឡើងថ្នាក់

**មាត្រា ១២.-**

ការដំឡើងឋានន្តរស័ក្តិ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈសម្បត្តិផ្ទាល់ខ្លួនរបស់មន្ត្រីសាមី និង ល័ក្ខខ័ណ្ឌបណ្តុះបណ្តាល ដោយមានសញ្ញាប័ត្រជាមូលដ្ឋាន ។ ការដំឡើងឋានន្តរស័ក្តិ ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង ឬថ្នាក់ដែលមានសន្ទស្សន៍ បៀវត្សខ្ពស់ លើបន្ទាប់ ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

ត្រូវដំឡើងពីឋានន្តរស័ក្តិទី៣ ទៅឋានន្តរស័ក្តិទី ២ ចំពោះមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលស្ថិតនៅក្នុងថ្នាក់លេខ ១១ ឡើងទៅ និងមានលក្ខណៈ សម្បត្តិណាមួយដូចខាងក្រោម :

- មាននិក្ខេបបទ
- មានសញ្ញាប័ត្រ :
  - បណ្ឌិតវេជ្ជសាស្ត្រទូទៅ ឬបណ្ឌិតវេជ្ជសាស្ត្រឯកទេស
  - បណ្ឌិតឱសថសាស្ត្រ ឬបណ្ឌិតឱសថសាស្ត្រឯកទេស ៖
  - បណ្ឌិតទន្តវេទសាស្ត្រ ឬបណ្ឌិតទន្តវេទសាស្ត្រឯកទេស

ឬសញ្ញាប័ត្រដទៃទៀតដែលមានតំលៃស្មើ ។

ត្រូវដំឡើងទៅក្នុងឋានន្តរស័ក្តិទី១ ចំពោះមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលស្ថិតនៅក្នុងថ្នាក់លេខ៧ឡើងទៅ នៃឋានន្តរស័ក្តិទី ២ ហើយដែលត្រូវទទួលការតែងតាំងជាសាស្ត្រាចារ្យមហាបរិញ្ញា ។

សញ្ញាប័ត្រឯកទេស ឬ សញ្ញាប័ត្រនានាខាងលើ ត្រូវមានការទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬ ក្រសួងអប់រំយុវជន និងកីឡា ។

ការដំឡើងពីឋានន្តរស័ក្តិទី៣ ទៅ ទី២ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការដំឡើងពីឋានន្តរស័ក្តិទី ២ ទៅទី ១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា ១៣.-**

ចំនួនមន្ត្រីក្របខ័ណ្ឌ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ទៅតាមបរិមាណជាក់ស្តែង ដោយផ្អែកលើលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ និង ល័ក្ខខ័ណ្ឌបណ្តុះបណ្តាលដោយមានសញ្ញាប័ត្រជាមូលដ្ឋានដូចមានចែងក្នុងមាត្រា១២ ខាងលើ ។

**មាត្រា ១៤.-**

ការដំឡើងថ្នាក់មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។ល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- ប្រសិទ្ធិភាពក្នុងការដឹកនាំ និង គ្រប់គ្រង
- សាមគ្គីធម៌ និងសីលធម៌រស់នៅ ។

ត្រូវបានដំឡើងថ្នាក់មួយថ្នាក់ ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស ចំពោះមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលក្រសួងបានចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាល រយៈពេលយ៉ាងតិច ០១ឆ្នាំ ដោយមានលិខិតបញ្ជាក់ការសិក្សា វិញ្ញាបនប័ត្រ ឬ សញ្ញាប័ត្រចេញដោយ គ្រឹះស្ថានបណ្តុះបណ្តាលនោះ ។

ការដំឡើងថ្នាក់មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសក្រសួងសុខាភិបាល ស្របតាមឋានន្តរស័ក្តិនៃមន្ត្រីសាមី ។

មាត្រា ១៥.-

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងតំលៃឯកតានៃសន្ទស្សន៍ ត្រូវបានកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យ លេខ នស /រកត/ ១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៨

## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៦.-

មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលមានស្នាដៃពិសេស ឬ ទទួលជោគជ័យក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រថ្មី ត្រូវទទួលការលើកសរសើរ ឬ រង្វាន់លើកទឹកចិត្តពីរាជរដ្ឋាភិបាល តាមករិតស្នាដៃជាក់ស្តែង ក្រៅពីការដំឡើងថ្នាក់ឬឋានន្តរស័ក្តិ ។

ក្នុងពេលបំរើការងារ មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រសកលវិទ្យាល័យ ត្រូវដំឡើងថ្នាក់មួយថ្នាក់ ជាស្វ័យប្រវត្តិ ។

មាត្រា ១៧.-

មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៦០ ឆ្នាំ ។

មាត្រា ១៨.-

សញ្ញាស័ក្តិ និង ឯកសណ្ឋាន សំរាប់មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៩.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រខាងវិស័យសុខាភិបាល ហើយបច្ចុប្បន្ន កំពុងបំពេញមុខងារនិងមុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាល នៅរដ្ឋបាលកណ្តាល និងខេត្ត ក្រុង របស់ក្រសួង ស្ថាប័នរដ្ឋ ផ្អែកតាមលក្ខណៈសម្បត្តិផ្ទាល់ខ្លួនរបស់មន្ត្រីរាជការ ដូចខាងក្រោម :

- បញ្ចូលក្នុងឋានន្តរស័ក្តិទី៣ ចំពោះមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រចេញពីមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ឬសញ្ញាប័ត្រសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ឬសញ្ញាប័ត្រផ្សេងទៀតដែលមានតំលៃស្មើ ។
- បញ្ចូលក្នុងឋានន្តរស័ក្តិ ទី២ ចំពោះមន្ត្រីរាជការដែល :
    - មាននិក្ខេបបទ –
    - មានសញ្ញាប័ត្រឯកទេស
    - ជាសាស្ត្រាចារ្យ ដែលតែងតាំងដោយក្រសួងសុខាភិបាល អោយបង្រៀន និង ណែនាំអនុវត្តមុខវិជ្ជាឯកទេសណាមួយ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និង អង្គភាពធ្វើកម្មសិក្សាអនុវត្តន៍ ហើយមានបទពិសោធន៍ការងារយ៉ាងតិច ១០ ឆ្នាំ
    - ជាប្រធាន ឬ អនុប្រធានអាសនៈសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
    - ជាមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដែលមានសមត្ថភាពខ្ពស់ ឆ្លងកាត់ការវាយតំលៃរបស់គណៈកម្មការបង្កើតឡើងដោយក្រសួងសុខាភិបាល ។
- បញ្ចូលក្នុងឋានន្តរស័ក្តិទី១ ចំពោះមន្ត្រីរាជការដែលបានទទួលការតែងតាំងជាសាស្ត្រាចារ្យដោយការប្រលងតាមនីតិវិធីដែលឆ្លងកាត់ការវាយតម្លៃ របស់ក្រុមប្រឹក្សាមេប្រយោគបង្កើតឡើងដោយក្រសួងសុខាភិបាល ។

**មាត្រា ២០.-**

មុខតំណែងគ្រប់គ្រងនីមួយៗ ដែលត្រូវអនុវត្តតាមគោលការណ៍ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ខ្ពស់ជាងគេ មិនមានប្រតិសកម្ម ទៅលើមុខដំណែងគ្រប់គ្រងបច្ចុប្បន្ន ដែលមានការតែងតាំងរួចហើយទេ លើកលែងតែមានការចាំបាច់ ដែលជាសមត្ថកិច្ចរបស់ក្រសួង ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។/.

មាត្រា ២២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ២៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

៣រល.០២.០៦.០០១៧៥

បានសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**